# សូមស្វាគមន៍ !

សូមស្វាគមន៍ចំពោះការចូលរួមរៀនពី**កញ្ចប់ឯកសារអប់រំបង្កើតព័ត៌មាន** ដែលជាកញ្ចប់ឯកសារ និងការបណ្តុះបណ្តាលជូនអ្នកផ្សព្វផ្សាយ អ្នកសារព័ត៌មានអំពីការអប់រំសំរាប់ទាំងអស់គ្នា។

**កញ្ចប់ឯកសារអប់រំបង្កើតព័ត៌មាន** នេះមានគោលបំណងជួយអ្នកឲ្យបង្កើនការយល់ដឹងឲ្យកាន់តែច្រើនអំពីសកម្មភាព និងដំណើរការនៃការអប់រំសំរាប់ទាំងអស់គ្នា និងជួយអ្នកឲ្យក្លាយទៅជាផ្នែកមួយនៃចលនាពិភពលោកដ៏សំខាន់នេះ។ ប្រសិនបើអ្នកជាអ្នកកាសែត ឬជាអ្នកប្រកបមុខរបរផ្សព្វផ្សាយព័ត៌មាន កញ្ចប់ឯកសារនេះនឹងផ្តល់ព័ត៌មានយ៉ាងច្រើនដើម្បីជាជំនួយដល់អ្នកក្នុងការសរសេររឿង សរសេរព័ត៌មាន ស្តីពីបញ្ហាអប់រំសំរាប់កាសែត ទស្សនាវដ្តី ស្ថានីយ៍វិទ្យុ និងស្ថានីយ៍ទូរទស្សន៍។ មានរឿងថ្មីៗ និងគួរឲ្យចាប់អារម្មណ៍ជាច្រើនកំពុងកើតមាននៅក្នុងវិស័យអប់រំ ។ ការអប់រំអាចបង្កើតនូវព័ត៌មានល្អៗជាច្រើនសំរាប់សារព័ត៌មាន ។

អ្នកអាចសិក្សាជាលក្ខណៈ "បុគ្គល" ឬក៏ប្រើប្រាស់ **កញ្ចប់ឯកសារអប់រំបង្កើតព័ត៌មាន** នេះដើម្បីរៀបចំសិក្ខាសាលារយៈពេលមួយថ្ងៃស្តីពីប្រធានបទអប់រំសំរាប់ទាំងអស់គ្នា។ គ្រូឧទ្ទេសនឹងរកឃើញនូវចំណុចសំខាន់ៗនៅទីនេះដើម្បីរៀបចំសិក្ខាសាលាឲ្យបានចប់សព្វគ្រប់ ដោយចំណុចសំខាន់ទាំងនោះរួមមាន កម្មវិធីសិក្សាប្រចាំថ្ងៃ សំភារៈឧបទ្ទេស និងបទឧទ្ទេសនាមដែលបានរៀបចំរួចជាស្រេច។ល។

ឥឡូវនេះ សូមមើលថាតើ **កញ្ចប់ឯកសារអប់រំបង្កើតព័ត៌មាន** នេះមានខ្លឹមសារបែបណាដែរ។